ខេត្តកាណាហ្គាវ៉ា

# បើជួបបញ្ហាក្នុងការ ចិញ្ចឹមនិងអប់រំកូន...



តោះរីករាយនឹងការចិញ្ចឹមកូនដោយការអប់រំដែលមិនពឹងលើការពិន័យលើរាងកាយ

មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារខេត្តកាណាហ្គាវ៉ា

カンボジア語

# សេចក្ដីផ្ដើម

## "ការពិន័យលើរាងកាយកូនគឺមិនបានទេ ពិតទេ?"

ពិតហើយ។ ច្បាប់ត្រូវបានធ្វើវិសោធនកម្មចែងថាមិនត្រូវប្រើការពិន័យលើរាងកាយ ក្នុងការអប់រំកូនឡើយ។

## "ប៉ុន្តែ បើធ្វើខុសហើយមិនវាយឲ្យយល់ទេ គឺខ្លាចទៅអនាគតមិនដឹងអាចក្លាយជាមនុស្សត្រឹមត្រូវឬអត់។"

អារម្មណ៍នោះគឺយើងយល់។ ប៉ុន្តែយើងបានយល់ថា ការពិន័យលើរាងកាយ ជាភាពអវិជ្ជមានចំពោះការលូតលាស់របស់កុមារ។

## "អ៊ីចឹង តើគួរធ្វើយ៉ាងម៉េច? ស្រឡាញ់កូនខ្លាំងប៉ុន្តែកំពុងមានកង្វល់ក្នុងការចិញ្ចឹមកូន។"

ការចិញ្ចឹមកូនរាល់ថ្ងៃគឺពិតជាពិបាកមែន។
កូនសៀវភៅនេះយើងបង្កើតឡើងដោយសង្ឃឹមថានឹងផ្ដល់ជាគន្លឹះក្នុងការចិញ្ចឹមកូនដោយមិនពឹងលើការពិន័យលើរាងកាយ ម្យ៉ាងទៀតគឺចង់ឆ្លើយតបទៅនឹងកង្វល់របស់លោកអ្នកដែលជាអាណាព្យាបាលទោះបីជាបន្តិចបន្តួចក្ដី។
នៅទីនេះ យើងនឹងណែនាំអំពីគ្រួសារគ្នា4នាក់ ដែលកំពុងចិញ្ចឹមកូនតែម្ដង។
តោះទៅមើលថាតើពួកគេកំពុងអប់រំនិងចិញ្ចឹមកូនបែបណា ប្រៀបធៀបនឹងការចិញ្ចឹមកូនរបស់លោកអ្នក។


ណែនាំតួអង្គ ........................................ 2P
រឿងគំនូរថ្លុក "គ្រួសារនៅថ្ងៃមួយ" ........................................ 3P
តោះរីករាយនឹងការចិញ្ចឹមកូនដោយការអប់រំដែលមិនពឹងលើការពិន័យលើរាងកាយ ........................................ 11P
កន្លែងប្រឹក្សានានា ........................................ 13P

# ណែនាំតួអង្គ



## ប៉ាប៉ា ឈ្មោះម៉ាម៉ូរុ អាយុ30ឆ្នាំ

មានគោលបំណងក្លាយជាបុរសដែលមើលថែកូនអោយបានជិតដល់ ប៉ុន្តែការងាររវល់មិនសូវមានពេលវេលានៅជាមួយកូន។ ពិបាកដោយសារហារុតុនៅមិនស្ងៀម ពេលខ្លះស្រែកដាក់កូននិងរហូតដល់វាយកូន។



## ម៉ាក់ម៉ាក់   ឈ្មោះអ៊ីគុយ៉ុ អាយុ28ឆ្នាំ

ជាម្តាយរួសរាយនិងចិត្តល្អ។ ពេលម៉េអាយុបាន1ឆ្នាំ ក៏បានចាប់ផ្តើមចូលធ្វើការងារឡើងវិញដោយដាក់កូននៅសាលាមត្តេយ្យ ប៉ុន្តែមួម៉ៅច្រើនដោយសារតែមមាញឹកនឹងការចិញ្ចឹមកូន, កិច្ចការផ្ទះ និងការងារ។



## កូនប្រុសច្បង   ឈ្មោះហារុតុ អាយុ4ឆ្នាំ

ជាក្មេងប្រុសសុខភាពល្អនិងរពើក ចូលរៀនសាលាមត្តេយ្យ។ ចូលចិត្តលេងនៅខាងក្រៅ ប៉ុន្តែមិនទាន់ចេះរៀបចំសម្អាតបានល្អទេ។



## កូនស្រីច្បង ម៉េ អាយុ1ឆ្នាំ

ជាក្មេងស្រីដែលចូលរៀនសាលាមត្តេយ្យដូចគ្នានឹងហារុតុ។ ចេះចាំពាក្យសម្តី ធ្វើតាមហារុតុនិងរួបរាងដើរតាមពីក្រោយគេសតាសគឺគួរឲ្យស្រឡាញ់។

## គ្រួសារនៅថ្ងៃមួយ

# ① ការរៀបចំសម្អាត









**ចំណុចសំខាន់**

ម៉ាក់បានស្រែកដាក់កូនដោយមិនដឹងខ្លួន ប៉ុន្តែគាត់ហាក់ដូចជាបានគិតឡើងវិញបន្តិច។ ជាការល្អដែលអាចរៀបចំសម្អាតជាមួយកូនដោយបង្ហាញពីអ្វីដែលកើតឡើងនៅខាងមុខដូចជាប្រាប់ពីមូលហេតុដែលត្រូវរៀបចំទុកជាដើម។

# ②ធ្វើខ្លួនឯង!


ហាស!?
ថ្ងៃនេះមានការប្រជុំត្រូវ
ឆាប់ទៅជាងរាល់ដងផង-
អត់ទាន់ពាក់
ស្រោមជើងផង


ស្រួតឡើង-
ម៉ាក់ជួយទេ?
ម៉ាក់-
តោះទៅ-
អត់ទេ!
កូនពាក់ខ្លួ
នឯង!




ចំណុចសំខាន់

វាពិបាកនៅពេលព្រឹកដែលរវល់ ប៉ុន្តែត្រូវទទួលស្គាល់ "អារម្មណ៍ចង់ធ្វើ" របស់កូន ហើយការរង់ចាំនឹងជំរុញទឹកចិត្តចង់ធ្វើឲ្យបានសម្រេចរបស់កូន ដែលនាំឲ្យអាចទៅសាលាដោយអារម្មណ៍ល្អ។

គ្រួសារនៅថ្ងៃមួយ

# ③គ្រោះថ្នាក់ណាស់!









ចំណុចសំខាន់

មនុស្សធំក៏ដូចគ្នាដែរ បើគិតថាធ្វើខុស, ជាការល្អបើអាចសុំទោសដូចឪពុកម្នាក់នេះ។ ការអាចប្រាប់ដោយងាយយល់ពីមូលហេតុគ្រោះថ្នាក់ចំពោះកូន គឺជាការល្អ។

## គ្រួសារនៅថ្ងៃមួយ ④ម៉ាក់ឈឺហើយ...












**ចំណុចសំខាន់**

នៅពេលមនុស្សធំមានបញ្ហាអ្វីដែលមិនអាចមើលក្មេងបាន នៅពេលធម្មតាត្រូវរកឲ្យបានអ្នកដែលអាចជួយមើលជំនួស នោះអ្នកនឹងអាចទុកចិត្តបាននៅពេលគេជួយក្នុងពេលបន្ទាន់។

តើទិដ្ឋភាពក្នុងរឿងគំនូរថ្លុក "គ្រួសារនៅថ្ងៃមួយ" យ៉ាងម៉េចដែរ?

មានឈុតដែលទាំងប៉ានិងម៉ាក់ចេះតែដំឡើងសំឡេងខ្លាំង ហើយពេលខ្លះវាយកូនទៀត។

ប៉ុន្តែគ្មានអ្នកណាដែលអាចចិញ្ចឹមកូនដោយល្អឥតខ្ចោះនោះទេ។ ចំណុចល្អរបស់គ្រួសារនេះគឺ ពេលបានខុសហើយដឹងកំហុសខ្លួនឯង បានសុំទោសកូនត្រឹមត្រូវ និងព្យាយាមប្តូរវិធីដោះស្រាយជាដើម។

**កូនពេលមើលឃើញឪពុកម្តាយដែលខំប្រឹងប្រែងដើម្បីខ្លួន, ធ្វើឲ្យក្តីស្រឡាញ់ជ្រាលជ្រៅ និងរៀនសូត្រថាអ្នកណាក៏បរាជ័យបណ្តើររីកចម្រើនដែរ។**

ប្រាកដណាស់ ការដោះស្រាយនឹងខុសគ្នាទៅតាមអាយុនិងអត្តចារិកកូន និងស្ថានភាព។ កូនរីកលូតលាស់ពីមួយថ្ងៃទៅមួយថ្ងៃ ហើយឪពុកម្តាយក៏កាន់តែយល់ដឹងពីមួយថ្ងៃទៅមួយថ្ងៃដែរ។ សូមរីករាយនឹងការចិញ្ចឹមកូនតាមបែបរបស់ខ្លួនហើយត្រូវនឹងកូនខ្លួនដោយសុំការជួយរបស់អ្នកជុំវិញផងដែរ។

ទោះជាបែបនេះក្តី ចំពោះលោកអ្នកដែលជាអាណាព្យាបាល ការចិញ្ចឹមកូនគឺមានសុទ្ធតែរឿងដែលជួបលើកដំបូង។ ជារឿងធម្មតាដែលភាន់ច្រលំនិងមានកង្វល់។ នៅពេលបែបនោះ សូមនឹកដល់រឿងគំនូរថ្លុក "គ្រួសារនៅថ្ងៃមួយ"។

បទអត្ថាធិប្បាយ

## ហេតុអ្វីបានជាមិនអាចពិន័យលើរាងកាយ?

តាមឯកសាររបស់ក្រសួងការងារនិងសុខុមាលភាពបានបង្ហាញនូវលទ្ធផលនៃការស្រាវជ្រាវដូច្នេះថា កុមារដែលទទួលរងការពិន័យលើរាងកាយពីឪពុកម្តាយ បើប្រៀបធៀបទៅនឹងកុមារដែលមិនបានទទួលរងសោះ មានទំនោរដូចជា **"មិនអាចស្តាប់ការនិយាយដោយស្ងប់អារម្មណ៍" "មិនអាចរក្សាសន្យា" "មិនអាចផ្តោតអារម្មណ៍លើកិច្ចការមួយបាន" "មិនអាចទ្រាំបាន" "មិនអាចបង្ហាញអារម្មណ៍បានល្អ" "មិនអាចធ្វើសកម្មភាពជាក្រុម"**។

ម្យ៉ាងទៀត ក៏ឃើញមានករណីដែលកុមារបានស៊ាំនឹងការឈឺចាប់ ហេតុនេះដើម្បីទទួលបានប្រសិទ្ធភាពដដែលគឺកាន់តែប្រើហិង្សាដែលបង្កទៅជាការធ្វើទារុណកម្មលើកុមារ។

# តើអ្នកមានកំពុងធ្វើរឿងទាំងនេះទេ?

**ទាំងអស់នេះគឺសុទ្ធតែការពិន័យលើរាងកាយ**

- បានព្រមានដោយពាក្យសម្ដី3ដងប៉ុន្តែដោយសារនិយាយមិនស្ដាប់ ក៏បានទះកំផ្លៀង
- កូនបានលេងសើចចំពោះរឿងសំខាន់ ហេតុនេះក៏បានឲ្យអង្គុយបត់ជើងយ៉ាងយូរ
- កូនបានវាយមិត្តភក្តិបណ្ដាលឲ្យរបួស ហេតុនេះក៏បានវាយកូនវិញដូចគ្នា
- កូនបានយករបស់គេ ហេតុនេះក៏បានវាយគូទកូន
- កូនមិនបានធ្វើកិច្ចការផ្ទះ ហេតុនេះមិនឲ្យញ៉ាំអាហារល្ងាច
- កូនមិនសម្អាត ហេតុនេះក៏បានយកកន្សែងជូតរុញផ្ទប់មុខ

**នេះជាទង្វើដែលបង្ករបួសផ្លូវចិត្តដល់កូន**

- ដោយក្នុងន័យនិយាយលេងសើច បាននិយាយពាក្យដែលមានលក្ខណៈបដិសេធវត្តមានរបស់កូនដូចជា"មិនបានកើតកូនមកដូចឯងល្អជាង"។
- ដោយប្រើមូលហេតុជំរុញទឹកចិត្តឲ្យខំប្រឹង បានលើកប្រៀបធៀបបងប្អូនជាឧទាហរណ៍

ដកស្រង់ពី

"យើងនាំគ្នាពង្រីកការចិញ្ចឹមកូនដោយមិនពឹងលើការពិន័យលើរាងកាយជាដើម!" របស់ក្រសួងការងារនិងសុខុមាលភាព

ពួកយើងនឹងជួយជ្រោមជ្រែងឲ្យអស់ពីលទ្ធភាពដល់ការរីកលូតលាស់របស់កូន និងការចិញ្ចឹមកូនរបស់លោកអ្នក។
សូមកុំក្រែងចិត្តក្នុងការប្រឹក្សានៅពេលជួបបញ្ហាដូចជា
**"កូននិយាយមិនស្ដាប់" "លើកដៃវាយកូនដោយមិនបានគិត" "ចង់ឲ្យស្ដាប់ពីកង្វល់ក្នុងការចិញ្ចឹមកូន"** ជាដើម។
គ្រាន់តែនិយាយចេញមក ក៏អារម្មណ៍ អាចនឹងធូរស្រាល។

នៅទំព័របន្ទាប់នេះ មានសរសេរពីកន្លែងប្រឹក្សានានាដែលលោកអ្នកអាចប្រឹក្សាបាន។ មិនត្រឹមតែស្ថាប័នទាំងនេះទេ នៅមណ្ឌលមើលថែកុមារ និងមជ្ឈមណ្ឌលគាំទ្រការចិញ្ចឹមកូន ក៏មានទទួលការប្រឹក្សាផងដែរ ហេតុនេះសូមសាកល្បងប្រើប្រាស់កុំបីខាន។



# កន្លែងប្រឹក្សានានា

## មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារខេត្តកាណាហ្គាវ៉ា

| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារ | ទូរសព្ទ | ដែនសមត្ថកិច្ច |
|---|---|---|
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារមជ្ឈិម | 0466-84-1600 | ក្រុងហ្ស៊ីជិសាវ៉ា, ក្រុងឈិហ្គាសាគិ, ស្រុកសាមីកាវ៉ា-ម៉ាឈិ |
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារហ៊ិរ៉ាឡិកា | 0463-73-6888 | ក្រុងហ៊ិរ៉ាឡិកា, ក្រុងហាតាណុ, ក្រុងអ៊ិសិហារ៉ា<br>ស្រុកអូអ៊ិសុ-ម៉ាឈិ, ស្រុកនិណុមិយ៉ា-ម៉ាឈិ |
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារតំបន់កាម៉ាគុរ៉ានិងមិអ៊ុរ៉ា | 046-828-7050 | ក្រុងកាម៉ាគុរ៉ា, ក្រុងហ្ស៊ុសិ, ក្រុងមិអ៊ុរ៉ា<br>ស្រុកហាយ៉ាម៉ា-ម៉ាឈិ |
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារអូដាវ៉ារ៉ា | 0465-32-8000 | ក្រុងអូដាវ៉ារ៉ា, ក្រុងមិណាមិអាស៊ិហ្គារ៉ា<br>ស្រុកណាកៃ-ម៉ាឈិ, ស្រុកអូអ៊ិ-ម៉ាឈិ<br>ស្រុកម៉ាឡិដា-ម៉ាឈិ, ស្រុកយ៉ាម៉ាគិតា-ម៉ាឈិ<br>ស្រុកកៃសេ-ម៉ាឈិ, ស្រុកហាកុណិ-ម៉ាឈិ<br>ស្រុកម៉ាណាហ្សុរ-ម៉ាឈិ, ស្រុកយុហ្គាវ៉ារ៉ា-ម៉ាឈិ |
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារអាឡិហ្គិ | 046-240-6430 | ក្រុងអាត្ស៊ឹហ្គិ, ក្រុងអិប៊ិណា, ក្រុងហ្សាម៉ា, ស្រុកអៃកាវ៉ា-ម៉ាឈិ, ភូមិគិយ៉ុកាវ៉ា-មឹរ៉ា |
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារតំបន់យ៉ាម៉ាតុ-អាយ៉ាសិ | 0466-81-8066 | ក្រុងយ៉ាម៉ាតុ, ក្រុងអាយ៉ាសិ |

## មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារតាមមូលដ្ឋានដទៃទៀតក្នុងខេត្ត

| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារ | ទូរសព្ទ | ដែនសមត្ថកិច្ច |
|---|---|---|
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារមជ្ឈិមក្រុងយ៉ូកូហាម៉ា | 045-260-6510 | សង្កាត់ឡិរុមិ-យុ, សង្កាត់កាណាហ្គាវ៉ា-យុ<br>សង្កាត់និស៊ិ-យុ, សង្កាត់ណាកា-យុ, សង្កាត់មិណាមិ-យុ |
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារភាគខាងលិច | 045-331-5471 | សង្កាត់ហុដុហ្គាយ៉ា-យុ, សង្កាត់អាសាហ៊ិ-យុ<br>សង្កាត់អ៊ិហ្សុមិ-យុ, សង្កាត់សិយ៉ា-យុ |
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារភាគខាងត្បូង | 045-831-4735 | សង្កាត់កូណាន់-យុ, សង្កាត់អ៊ិសុហ្គុ-យុ<br>សង្កាត់កាណាហ្សាវ៉ា-យុ, សង្កាត់តុឡិកា-យុ<br>សង្កាត់សាកាអិ-យុ |
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារភាគខាងជើង | 045-948-2441 | សង្កាត់កុហុគុ-យុ, សង្កាត់មិដុរិ-យុ, សង្កាត់អាអុបា-យុ, សង្កាត់ឡិហ្សិគិ-យុ |
| មជ្ឈមណ្ឌលកុមារនិងគ្រួសារក្រុងកាវ៉ាសាគិ | 044-542-1234 | សង្កាត់កាវ៉ាសាគិ-យុ, សង្កាត់សៃវ៉ៃ-យុ<br>សង្កាត់ណាកាហារ៉ា-យុ |
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារភាគកណ្តាល | 044-877-8111 | សង្កាត់តាកាឡិ-យុ, សង្កាត់មិយ៉ាម៉ាអិ-យុ |
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារភាគខាងជើង | 044-931-4300 | សង្កាត់តាម៉ា-យុ, សង្កាត់អាសាអុ-យុ |
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារក្រុងសាហ្គាមិហារ៉ា | 042-730-3500 | ក្រុងសាហ្គាមិហារ៉ា |
| មជ្ឈមណ្ឌលប្រឹក្សាអំពីកុមារក្រុងយ៉ុកុស៊ុកា | 046-820-2323 | ក្រុងយ៉ុកុស៊ុកា |

## ខ្សែទូរសព្ទប្រឹក្សានានា

| ខ្សែទូរសព្ទប្រឹក្សា | ទូរសព្ទ | ផ្សេងៗ |
|---|---|---|
| កុមារនិងគ្រួសារ លេខ110 | 0466-84-7000 | 9:00 - 20:00 |
| ខ្សែហាតឡាញសិទ្ធិមនុស្សនិងកុមារ | 0466-84-1616 | 9:00 - 20:00 (សម្រាប់កុមារ • សម្រាប់វាយការណ៍) |
| ខ្សែទំនាក់ទំនងឆ្លើយតបនឹងទារុណកម្មនៃមជ្ឈមណ្ឌលប្រឹក្សាអំពីកុមារ | 189 (ឥតគិតថ្លៃ) | ឆ្លើយតប24ម៉ោង |
| ខ្សែទំនាក់ទំនងសម្រាប់ប្រឹក្សានៃមជ្ឈមណ្ឌលប្រឹក្សាអំពីកុមារ | 0120-189-783 (ឥតគិតថ្លៃ) | |

# ច្រកការិយាល័យនៃក្រុងស្រុកឃុំសង្កាត់

| ក្រុងស្រុកឃុំសង្កាត់ | ផ្នែកទទួលបន្ទុក | ខ្សែទំនាក់ទំនងផ្ទាល់ផ្នែកទទួលបន្ទុកប្រឹក្សាអំពីកុមារ |
|---|---|---|
| ក្រុងហ៊ិរ៉ាឡិកា | ផ្នែកកុមារនិងគ្រួសារ | 0463-21-9843 |
| ក្រុងកាម៉ាគុរ៉ា | ផ្នែកប្រឹក្សាអំពីកុមារ | 0467-23-0630 |
| ក្រុងហ្វ៊ុជិសាវ៉ា | ផ្នែកកុមារនិងគ្រួសារ | 0466-50-3569 |
| ក្រុងអូដាវ៉ារ៉ា | ផ្នែកគាំទ្រកុមារនិងយុវជន | 0465-46-6763 |
| ក្រុងឈិហ្គាសាគិ | ផ្នែកប្រឹក្សាការអប់រំចិញ្ចឹមកូន<br>(ការិយាល័យប្រឹក្សាគ្រួសារនិងកុមារក្រុងឈិហ្គាសាគិ) | 0467-81-7170 |
| ក្រុងហ្ស៊ុសុិ | ផ្នែកគាំទ្រការចិញ្ចឹមកូន | 046-873-1111 (ខ្សែរួម) |
| ក្រុងមិអ៊ុរ៉ា | ផ្នែកកុមារ<br>មជ្ឈមណ្ឌលប្រឹក្សាមាតាបិតានិងកុមារ ហ៊ិណាតាបុកកុ | 046-882-1111 (ខ្សែរួម) |
| ក្រុងហាតាណុ | ផ្នែកគាំទ្រកុមារនិងគ្រួសារ (ខ្សែទំនាក់ទំនងសម្រាប់ប្រឹក្សា) | 0463-82-5273<br>0463-84-7800 |
| ក្រុងអាឡ៊ុហ្គិ | ផ្នែកប្រឹក្សាអំពីគ្រួសារ (ខ្សែទំនាក់ទំនងសម្រាប់ប្រឹក្សា) | 046-221-0181·0182 |
| ក្រុងយ៉ាម៉ាតុ | ផ្នែកចិញ្ចឹមកូនឲ្យបានល្អ | 046-260-5618 |
| ក្រុងអ៊ិសិហារ៉ា | ផ្នែកប្រឹក្សាអំពីកុមារនិងគ្រួសារ | 0463-94-4642 |
| ក្រុងអិប៊ិណា | ផ្នែកប្រឹក្សាការចិញ្ចឹមកូន | 046-235-4825 |
| ក្រុងហ្សាម៉ា | ផ្នែកកុមារនិងគ្រួសារ | 046-252-8026 |
| ក្រុងមិណាមិអាស៊ិហ្គារ៉ា | ផ្នែកកុមារ | 0465-73-8072 |
| ក្រុងអាយ៉ាសិ | ផ្នែកលើកកម្ពស់សុខភាព | 0467-77-1133 |
| ស្រុកហាយ៉ាម៉ា-ម៉ាឈិ | ផ្នែកអប់រំចិញ្ចឹមកូន | 046-876-1111 (ខ្សែរួម) |
| ស្រុកសាមុកាវ៉ា-ម៉ាឈិ | ផ្នែកគាំទ្រការចិញ្ចឹមកូន | 0467-74-1111 (ខ្សែរួម) |
| ស្រុកអូអ៊ិសុ-ម៉ាឈិ | ផ្នែកគាំទ្រការចិញ្ចឹមកូន(មជ្ឈមណ្ឌលគាំទ្រការចិញ្ចឹមកូនទូទៅ) | 0463-71-3377 |
| ស្រុកនិណុមិយ៉ា-ម៉ាឈិ | ផ្នែកចិញ្ចឹមកូននិងសុខភាព | 0463-71-7100 |
| ស្រុកណាកៃ-ម៉ាឈិ | ផ្នែកសុខុមាលភាព | 0465-81-5548 |
| ស្រុកអូអ៊ិ-ម៉ាឈិ | ផ្នែកចិញ្ចឹមកូននិងសុខភាព | 0465-83-8012 |
| ស្រុកម៉ាឡ៊ុដា-ម៉ាឈិ | ផ្នែកចិញ្ចឹមកូននិងសុខភាព | 0465-84-5544 |
| ស្រុកយ៉ាម៉ាគិតា-ម៉ាឈិ | ផ្នែកសុខុមាលភាព | 0465-75-3644 |
| ស្រុកកៃសេ-ម៉ាឈិ | ផ្នែកចិញ្ចឹមកូននិងសុខភាព | 0465-84-0327 |
| ស្រុកហាកុណិ-ម៉ាឈិ | ផ្នែកគាំទ្រការចិញ្ចឹមកូន | 0460-85-9595 |
| ស្រុកម៉ាណាហ្ស៊ុរុ-ម៉ាឈិ | ផ្នែកសុខុមាលភាព | 0465-68-1131 (ខ្សែរួម) |
| ស្រុកយុហ្គាវ៉ារ៉ា-ម៉ាឈិ | មជ្ឈមណ្ឌលគាំទ្រការចិញ្ចឹមកុមារ(យុតាប៉ុន) ផ្នែកគាំទ្រកុមារ | 0465-20-4940 |
| ស្រុកអៃកាវ៉ា-ម៉ាឈិ | ផ្នែកគាំទ្រការចិញ្ចឹមកូន | 046-285-6932 |
| ភូមិគិយ៉ុកាវ៉ា-មុរ៉ា | ផ្នែកថែរក្សាសុខភាពនិងសុខុមាលភាព | 046-288-3861 |



## បណ្ដាញសង្គមLINE ប្រឹក្សាអំពីកុមារនិងគ្រួសារកាណាហ្គាវ៉ា លេខ 110

LINE

សូមអែដប្រៀនតាមបណ្ដាញសង្គមខាងលើ

អាចប្រឹក្សាដោយឥតគិតថ្លៃនិងមិនបញ្ចេញឈ្មោះពិត (តែរូបអាយខុននិងឈ្មោះអាខោនក្នុងLINE)។

【ពេលវេលាទទួលប្រឹក្សា】(លើកលែងថ្ងៃចុងឆ្នាំនិងដើមឆ្នាំ)

ពីថ្ងៃចន្ទដល់សៅរ៍ ចាប់ពីម៉ោង9ព្រឹកដល់ម៉ោង9ល្ងាច

**Other Languages**

| | | | | |
|---|---|---|---|---|
| English 英語 | 中国语 中国語 | 한국·조선어 韓国・朝鮮語 | Español スペイン語 | Português ポルトガル語 |
| Tagalog タガログ語 | ภาษาไทย タイ語 | Tiếng Việt ベトナム語 | ភាសាខ្មែរ カンボジア語 | ພາສາລາວ ラオス語 |


監　　修　子どもの虹情報研修センター　川﨑二三彦
日本女子大学名誉教授　鵜養美昭
武蔵野大学看護学部　中板育美

作成・発行　神奈川県児童相談所

デザイン・印刷　有限会社 湘南グッド